សម្រាប់ផ្សព្វផ្សាយជាបន្ទាន់

មូលនិធិព្រះពុទ្ធសាសនាខ្មែរត្រូវបានបើកដំណើរការ

ការបរិច្ចាគជិតកន្លះលានដុល្លារសម្រាប់ជំនួយសង្គ្រោះដល់ជម្ងឺកូវីត- ១៩ នៅកម្ពុជា។

ឃោសនាហៅបណ្តាអង្គការនានាចូលរួមខិតខំប្រឹងប្រែងទាំងអស់គ្នា

**San Francisco, CALIFORNIA** – ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២១ - អ្នកនៅ San Francisco ជាសប្បុរសជន និងជាអ្នកឧបត្ថម្ភ ប្រជាជនកម្ពុជា ។ **Lyna Lam** ជាអ្នកបង្កើតមូលនិធិពុទ្ធសាសនាខ្មែរ ជាអង្គការមួយមិនស្វែងរកប្រាក់ចំណេញ និងដើម្បីលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជនខ្មែរ ហើយជួយថែរក្សាវប្បធម៌ ប្រពៃណីរបស់ខ្លួន ។ ខ្មែរមានដើមកំណើតមកពីអាស៊ី អាគ្នេយ៍ ភាគច្រើនជាប្រជាជនកម្ពុជា ។

សកម្មភាពដំបូងរបស់អង្គការគឺបរិច្ចាគអំណោយជិត ៥០០.០០០ ដុល្លារដើម្បីគាំទ្រប្រជាជនកម្ពុជាដែលរងផលប៉ះពាល់ដោយជំងឺរាតត្បាត - កូវីត- ១៩ ។ ការបរិច្ចាគនេះ ដើម្បីផ្គត់ផ្គង់នូវតម្រូវការចាំបាច់ជាច្រើនរួមមានម៉ាស៊ីនជំនួយបំពង់ខ្យល់និងឧបករណ៍តាមដានអ្នកជម្ងឺ ដើម្បីបំពេញសេចក្តីត្រូវការ ប្រទេសមួយដែលកំពុងដោះស្រាយជាមួយនឹងផលប៉ះពាល់ការបំផ្លិចបំផ្លាញនៃជំងឺរាតត្បាត។

ក្រៅអំពីឧបករណ៍វេជ្ជសាស្រ្ត នៅមួយចំណែកទៀតគឺឧបត្ថម្ភស្បៀងនិងជំនួយដល់កុមារ យុវជន ដែលមានជីវភាពក្រលំបាក និងក្រុមគ្រួសាររបស់ពួកគេ ។ អំណោយមនុស្សធម៌គឺបានគ្រប់គ្រងតាមរយៈ អង្គការមិត្តភាពអន្តរជាតិ មានមូលដ្ឋាននៅប្រទេសកម្ពុជា ដែលបានជួយសង្គ្រោះជីវិតនិងកសាងអនាគត កុមារ និង យុវជន ដែលងាយរងគ្រោះបំផុត ។ គ្រួសារនិងសហគមន៍របស់ពួកគេ នៅ អាស៊ីអាគ្នេយ៍ ទូទាំងពិភពលោកក្នុងរយៈកាល២៦ឆ្នាំនេះ ។

អំណោយនេះត្រូវបានធ្វើឡើងជាដៃគូរបស់ Digital Divide Data (DDD) ជាអ្នកវិនិយោគបច្ចេកវិទ្យាធំបំផុតនៅកម្ពុជា ដែលជាគំរូមួយដល់សង្គម ប្រកបដោយភាពច្នៃប្រឌិតជួយអោយយុវជន ដែលមានទេពកោសល្យ ពីគ្រួសារដែលមានប្រាក់ចំណូលទាប អាចទទួលបានឱកាសការ ការងារនិងទទួលបានប្រាក់ចំណូលខ្ពស់ហើយយូរអង្វែង ។

Lyna ដែលជាស្ថាបនិកនិងជានាយកប្រតិបត្តិនៃមូលនិធិពុទ្ធសាសនាខ្មែរ មានប្រសាសន៍ថា “ពួកយើងក៏ព្រួយបារម្ភដែរ ពេលបានដឹងពីស្ថានភាព ជម្ងឺកូវីត-១៩ ដែលគម្រាមកំហែងនៅកម្ពុជា “ ពួកយើងដឹងថា ប្រជាជនកម្ពុជាមានប្រវត្តិតស៊ូ រឹងមាំ នឹងងើបឡើងវិញក្រោយការលំបាកទាំងនោះ ប៉ុន្តែយើងខ្ញុំក៏

ដឹងដែរថា បើមានកម្លាំងជំនួយបន្ថែមនិងជួយកាត់ផ្តាច់ជម្ងឺដ៏កាចចង្រៃនេះ ។ យើងខ្ញុំជឿជាក់ថា រឿងដែរសំខាន់ ប្រជាជនខ្មែរ ដើមកំណើតខ្មែរដែលរស់នៅសហរដ្ឋអាមេរិក និងជួយកម្ពុជា តាមលទ្ធភាពនិងមធ្យោបាយដែលពួកគេអាចធ្វើទៅបាន ។ ដូចជាប្រជាជនអាមេរិកដើមកំណើតឥណ្ឌា ដ៏ក្លាហានអង់អាច និងជំនួយដល់វិបត្តិកូវីត នៅឥណ្ឌា ។

ទោះបី ការបរិច្ចាកលើកដំបូងត្រូវបានគ្រោងទុកសម្រាប់ជួយសង្គ្រោះក្នុងវិបត្តិ កូវីត- ១៩ ក៏ដោយ ។ ប៉ុន្តែមូលនិធិនេះ មានគោលបំណង ក្នុងការឧបត្ថម្ភជានូវសកម្មភាពដ៏សំខាន់ដល់ប្រជាជនកម្ពុជា ជាច្រើនទៀត ដូច ផ្នែកសិល្បៈនិងវប្បធម៌ ការផ្តល់ជំនួយដល់អាជីវកម្មថ្មី ការគាំទ្រសហគមន៍និងការសិក្សានៅមហាវិទ្យាល័យ ។

មូលនិធិនេះកំពុងទទួលយកការជំនួយ សម្រាប់ជួយដល់វិបត្តិកូវីត-១៩ និងសូមអំពាវនាដល់សប្បុរសជនណាដែលមានកម្លាំងធនធានសូមជួយឧបត្ថម្ភផង ៗ

ការជំនួយឧបត្ថម្ភអាចធ្វើឡើងនៅទីនេះ : https://www.akhmerbuddhistfoundation.org/donate-khmer

## **អំពី Lyna Lam**

Lyna Lam បានមកដល់ជំរុំជនភាសខ្លួន បន្ទាប់ពីសង្គ្រាមវៀតណាមនិងអំពើប្រល័យពូជសាសន៍កម្ពុជា ។ ជាច្រើននៃការខិតខំប្រឹងប្រែងឧស្សាហ៍ព្យាយាម  បាននាំមកនូវជោគជ័យដល់អាជីវកម្មខ្នាតតូច ហើយអ្នកស្រីបានចាប់ផ្តើមបង្កើតមូលដ្ឋានគ្រឹះ ដោយសារតែនាងបានឃើញដោយផ្ទាល់ពីរបៀបជំនួយថវិកាតិចតួច មួយចំនួនអាចផ្លាស់ប្តូរជីវិតក្រលំបាក ទៅជាចេះពង្រឹងសមត្ថភាពនិងវិភាគទាន ។

កាលពីមុន Lam និងស្វាមី Chris Larsen បានឧបត្ថម្ភ ២៥លានដុល្លារ ទៅមហាវិទ្យាល័យពាណិជ្ជកម្មនៃសកលវិទ្យាល័យ San Francisco ( បច្ចុប្បន្នជាមហាវិទ្យាល័យពាណិជ្ជកម្ម ដែលរួមចំណែកគ្រួសារ Lam ) 37% នៃនិស្សិតគឺជានិស្សិតដំបូង ក្នុងគ្រួសារដែលបានចូលរៀននៅមហាវិទ្យាល័យនេះ ។ នាងក៏ជាអ្នកឧបត្ថម្ភពាន់រង្វាន់ **Larsen Lam ICONIQ Impact Award**, ដែលបានបង្កើតឡើងដើម្បីគាំទ្រ ដំណោះស្រាយចំពោះវិបត្តិជនភាសន៍ខ្លួនរបស់ពិភពលោក ។ លើសពីនេះ  អ្នកស្រីកំពុងតែផ្តល់ជំនួយដល់កម្មវិធីមួយ គឺស្រាវជ្រាវឯកសារសាស្ត្រាទាំងអស់និយាយពីអក្សរសាស្ត្រខ្មែរដែលនៅសេសសល់ ដែលជាឯកសារដ៏សំខាន់ដើម្បីអភិរក្សនូវវប្បធម៌ខ្មែរ ។ បច្ចុប្បន្ននេះ អ្នកស្រីកំពុងតែដំណើរការកសាងវត្តមួយ ដែលជាមូលដ្ឋានគ្រឹះរបស់វប្បធម៌ខ្មែរនៅ San Jose, California .

## **អំពីមូលនិធិពុទ្ធសាសនាខ្មែរ**

មូលនិធិពុទ្ធសាសនាខ្មែរគឺជាអង្គការមិនស្វែងរកប្រាក់ចំណេញមួយដែលផ្តោតលើការលើកកំពស់ជីវភាពរបស់ប្រជាជនខ្មែរនិងថែរក្សាប្រពៃណីនិងវប្បធម៌ដ៏សំបូរបែបរបស់ខ្លួន ។ នឹងបានផ្តល់នូវជំនួយជារៀងរាល់ឆ្នាំដើម្បីពង្រឹង ជីវភាពរស់នៅរបស់ប្រជាជនខ្មែរនៅក្នុងវិស័យ សិល្បៈនិងវប្បធម៌និងជំនួញ ការសិក្សារៀនសូត្រ ។ ស្វែងយល់បន្ថែម : www.akhmerbuddhistfoundation.org

######

ទំនាក់ទំនងប្រព័ន្ធផ្សព្វផ្សាយ :

Birgit Johnston

birgitjohnston@me.com, 408 656-8025